## សាកលវិទ្យាល័យខេមរៈ

### មហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ

# ទំនាក់ទំនងនយោបាយកម្ពុជា-សហរដ្ឋអាមេរិក

(១៩៥០-២០១៦)

# POLITICAL RELATIONS OF CAMBODIA AND UNITED STATES OF AMERICA

(1950-2016)

**និក្ខេបបទថ្នាក់បណ្ឌិត**

**ឯកទេស ៖ វិទ្យាសាស្ត្រនយោបាយ**

**បណ្ឌិត ស៊ីន សំ**

**សាស្ត្រាចារ្យណែនាំ៖** - បណ្ឌិតសភាចារ្យ **សុខ ទូច**

- បណ្ឌិត **រស់ វ៉ាឌុច**

**ភ្នំពេញ ២០១៩**

# មាតិកា

ឧទ្ទិសវាចា ........ i
សេចក្តីថ្លែងអំណរគុណ ........ ii
អំណះអំណាង ........ iii
មូលន័យសង្ខេប ........ iv
Abstract ........ vi
សេចក្តីសង្ខេប ........ vii
Summary ........ ix
អក្សរកាត់ ........ xi
លំនាំដើម ........ xii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទនៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រស្រាវជ្រាវ ........ ៣
៥.១.វិធីសាស្ត្រស្រាវជ្រាវ ........ ៣
៥.២.ឯកសារតម្រង់ទិស ........ ៤
៦. សារៈប្រយោជន៍នៃការស្រាវជ្រាវ ........ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

## ជំពូក១
## ប្រវត្តិទំនាក់ទំនងកម្ពុជា-អាម៉េរិក

១. ទំនាក់ទំនងនយោបាយកម្ពុជាអាម៉េរិក ........ ៧
១.១.ទំនាក់ទំនងនយោបាយកម្ពុជាអាម៉េរិកនៅឆ្នាំ១៩៥០ ........ ១២
១.២.នយោបាយរបស់សម្តេចព្រះនរោត្តមសីហនុ ........ ១៦
១.២.១.សកម្មភាពដើម្បីស្វែងរកការគាំទ្ររបស់សម្តេចសីហនុ ........ ១៩
១.២.២.នយោបាយមិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា ........ ២៤
១.៣.ទំនាក់ទំនងនយោបាយកម្ពុជាអាម៉េរិកនៅឆ្នាំ១៩៧០-៧៩ ........ ២៨
១.៣.១.ការបែកបាក់រវាងសហរដ្ឋអាម៉េរិក និងសម្តេចសីហនុ ........ ៣២
១.៤.ទំនាក់ទំនងនយោបាយកម្ពុជាអាម៉េរិកនៅឆ្នាំ១៩៨០ ........ ៣៦
១.៥.ទំនាក់ទំនងនយោបាយកម្ពុជាអាម៉េរិកនៅឆ្នាំ២០០០ ........ ៤៤
២. ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជាអាម៉េរិក ........ ៤៨
២.១. សេដ្ឋកិច្ចកម្ពុជា ........ ៤៨

២.២.ទំនិញកម្ពុជាទៅលក់ក្នុងទីផ្សារអាម៉េរិក ........ ៤៩
២.៣.ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជាអាម៉េរិក ........ ៥០
៣.ជំនួយអាម៉េរិកនៅកម្ពុជា ........ ៥១
៣.១.លក្ខខន្ឌនៃជំនួយរបស់អាម៉េរិកចំពោះប្រទេសកម្ពុជា ........ ៥១
៣.២.អ្នកស្ម័គ្រចិត្ត Peace Corps ........ ៥៤
៣.៣.ក្រសួងការពារជាតិសហរដ្ឋអាម៉េរិក ........ ៥៤
៣.៤.លទ្ធផលបច្ចុប្បន្នភាព ........ ៥៧
៣.៥. សារៈសំខាន់នៃជំនួយ ........ ៦០
៣.៦.ជំនួយក្លាយជាបំណុល ........ ៦៤
៤.ទំនងទំនងយោធាកម្ពុជាអាម៉េរិក ........ ៦៧
៤.១. សារៈសំខាន់នៃភូមិសាស្ត្រនយោបាយកម្ពុជា ........ ៧២
៤.២.ភាពឆ្លាតវៃនៃការប្រើប្រាស់ភូមិសាស្ត្រនយោបាយ ........ ៧៣

## ជំពូក២
## នយោបាយកម្ពុជា និងទំនាក់ទំនងជាមួយសហរដ្ឋអាម៉េរិក

១.មរតកនយោបាយរបស់សម្តេចព្រះនរោត្តមសីហនុ ........ ៨៣
២.សេរីភាពសាសនានៅកម្ពុជា ........ ៨៤
៣.វិបត្តិនយោបាយកម្ពុជាអាម៉េរិកក្រោមឥទ្ធិពលជម្លោះដីធ្លី ........ ៨៩
៤.វិបត្តិនយោបាយកម្ពុជាអាម៉េរិកក្រោមឥទ្ធិពលសិទ្ធិមនុស្ស ........ ៩៥
៥.ទំនាក់ទំនងបែបទឹកនិងប្រេងរវាងកម្ពុជានិងអាម៉េរិក ........ ៩៦
៦. អាម៉េរិក និងគោលនយោបាយងាកទៅរកអាស៊ី ........ ១០០
៦.១.អាម៉េរិក និងបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា ........ ១០៣
៦.២.គោលនយោបាយអាម៉េរិកជាមួយអតីតគូសត្រូវ ........ ១០៨
៦.៣.តំលៃគោលនយោបាយការបរទេសអាម៉េរិក ........ ១១១
៧.ស្ថានភាពនយោបាយការបរទេសកម្ពុជា ........ ១១៤
៧.១.ទ្រឹស្តីនិងការអនុវត្តន៍ ........ ១១៨
៧.១.១.ការអនុវត្តទោសចំពោះមន្ត្រីការទូត ........ ១២០
៧.១.២.ការប្រតិកម្មបែបការទូត ........ ១២៣
៧.១.៣.តួនាទីការទូតកម្ពុជាលើឆាកអន្តរជាតិ ........ ១២៦
៧.១.៤.វិបត្តិការទូតកម្ពុជា ........ ១៣០
៧.១.៥.ប្រយោជន៍ការទូតសម្រាប់កម្ពុជា ........ ១៣២
៧.១.៦.ការរងគ្រោះក្នុងវិស័យការទូតរបស់កម្ពុជា ........ ១៣៣
៧.១.៧. សមុទ្រចិនខាងត្បូង និងការរងគ្រោះរបស់កម្ពុជា ........ ១៣៥
២.១.៧.១.តួនាទីអាម៉េរិក ក្នុងបញ្ហាសមុទ្រចិនខាងត្បូង ........ ១៣៦
៨.បញ្ហាប្រឈមថ្មីរវាងអាម៉េរិកនិងកម្ពុជា ........ ១៤១
៨.១.ព្រះមហាក្សត្រកម្ពុជា និងឥទ្ធិពលការទូត ........ ១៤៥

៨.២.សេដ្ឋកិច្ច និងឯករាជ្យកម្ពុជា ........ ១៤៨
៨.៣.ជំនួយ និការវិនិយោគពីបរទេស ........ ១៥៥
៨.៤.កិច្ចព្រមព្រៀងអន្តរជាតិ និងនិន្នាការការអភិវឌ្ឍ ........ ១៥៩
៨.៥.និន្នាការជំនួយអភិវឌ្ឍន៍ ........ ១៦២
៨.៥.១.ឱកាសនិងការប្រឈមនៃការប្រើប្រាស់ជំនួយ ........ ១៦៣

## ជំពូក ៣
## បញ្ហាប្រឈម និងទស្សនៈវិស័យ

១.ការប្រែប្រួលនយោបាយកម្ពុជាអាម៉េរិក ........ ១៦៩
១.១.ការប្រុងប្រយ័ត្នក្នុងវិស័យនយោបាយកម្ពុជា ........ ១៧១
១.២.នយោបាយដែលកម្ពុជាគួរមាន ........ ១៧៨
២. ការប្រកួតប្រជែងរវាងចិន និងសហរដ្ឋអាម៉េរិកនៅកម្ពុជា ........ ១៩០
២.១.ទំនាក់ទំនងសង្ខេបកម្ពុជា-ចិន ........ ១៩១
២.២.កម្ពុជា និងគោលនយោបាយចិនតែមួយ ........ ២០២
២.៣.គោលនយោបាយការពារសម្ព័ន្ធមិត្តរបស់អាម៉េរិក ........ ២០៤
៣.គោលនយោបាយអាម៉េរិកចំពោះអាស៊ាន ........ ២១៣
៤.ដំណោះស្រាយនយោបាយកម្ពុជាអាម៉េរិក ........ ២១៨
៤.១.នយោបាយកម្ពុជាអាម៉េរិកក្នុងរយៈពេលជិត ៧០ ឆ្នាំ ........ ២២៥

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន ........ ២៣០
២.អនុសាសន៍ ........ ២៣១
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# ឧទ្ទិសវាចា

ខ្ញុំសូមឧទ្ទិសនូវស្នាដៃ នៃការស្រាវជ្រាវថ្នាក់បណ្ឌិតរបស់ខ្ញុំនេះ ជូនគ្រូឧបជ្ឈាយ៍ ជីដូនជីតា បុព្វការីជន និងអ្នកប្រាជ្ញខ្មែរ ដែលបានបន្សល់ស្នាដៃដល់កូនចៅជំនាន់ក្រោយបានសិក្សារៀនសូត្រ ដើម្បីបានជាប្រយោជន៍ដល់ការយល់ដឹង និងការបណ្ដុះអ្នកប្រាជ្ញជំនាន់ក្រោយទៀត។

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដែលបានបង្ហាត់បង្រៀន និងបានបំពេញនូវការងារជាច្រើនសម្រាប់ប្រទេសជាតិ ហើយលោកគ្រូបានបង្ហាត់បង្ហាញនូវចំណេះដឹងផ្នែកនយោបាយដល់រូបខ្ញុំ ជាពិសេសលោកគ្រូបានយល់ព្រមធ្វើជា សាស្ត្រាចារ្យណែនាំខ្ញុំ ក្នុងការសរសេរនិក្ខេបបទនេះ។ ខ្ញុំបានសិក្សាចំណេះដឹង និងបានយល់ដឹងអំពីកិច្ចការជាច្រើន ជាពិសេស ខ្ញុំមានឱកាសបានស្គាល់មនុស្សសំខាន់ៗក្នុងប្រទេសកម្ពុជា អាស្រ័យដោយបានឱកាសធ្វើការក្រោមការដឹកនាំរបស់លោកគ្រូបណ្ឌិតសភាចារ្យ។

ខ្ញុំសូមអរគុណដល់លោកសាស្ត្រាចារ្យបណ្ឌិត **រស់ វ៉ាឌុធ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ**ខេមរៈ** ដែលបានព្រមធ្វើជាសាស្ត្រាចារ្យណែនាំរង ក្នុងការសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតរបស់ខ្ញុំនេះ។ ខ្ញុំពិតជាអរគុណណាស់ ដែលក្នុងពេលកន្លងមកលោកគ្រូបានជួយពន្យល់ណែនាំមេរៀន ជាពិសេសលោកគ្រូតែងតែបានយកចិត្តទុកដាក់ ក្នុងការណែនាំដល់ការសរសេរនិក្ខេបបទបណ្ឌិតរបស់ខ្ញុំនេះ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **យស់ ពៅ** អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា និងឯកឧត្តមបណ្ឌិត **គិន ភា** ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលឯកឧត្តមទាំងពីរបានធ្វើជាថ្នាក់ដឹកផង និងជាគ្រូបង្ហាញផ្លូវដល់រូបខ្ញុំផង ព្រោះខ្ញុំបានសិក្សារៀនសូត្រជាច្រើនអំពីសំណាក់លោកគ្រូទាំងពីរ ទាំងផ្នែកកិច្ចការអន្តរជាតិ និងការងាររដ្ឋបាល។

ខ្ញុំសូមអរគុណដល់លោកឪពុក អ្នកម្តាយ បង្កើត-ក្មេក ដែលបានជួយលើកទឹកចិត្ត ក្នុងការសិក្សា និងក្នុងជីវិតនៃការរស់នៅជាប្រចាំរបស់ខ្ញុំ។

ជាពិសេសជាងគេបំផុត ខ្ញុំសូមអរគុណដល់ភរិយារបស់ខ្ញុំ **ឈីន ស្រីនាង** ដែលបានជួយសម្រួលដល់ការសិក្សា ថ្នាក់បណ្ឌិតនេះ ព្រោះថា បើសិនជាប្រពន្ធមិនអនុញ្ញាត និងមិនជួយជ្រោមជ្រែងទាំងថវិកា និងការលើកទឹកចិត្តនោះទេ ការសិក្សាថ្នាក់បណ្ឌិតនេះ ពិតជាមិនអាចបញ្ចប់បានទេ។

ជាចុងក្រោយ ខ្ញុំសូមអរគុណ ដល់មិត្តទាំងអស់ ដែលបានសិក្សាជាមួយគ្នា ហើយបានបង្កើតជាក្រុមមួយដែលមានសម្ព័នភាពស្និទ្ធស្នាល ជាពិសេសគឺការសន្ទនា ភាសានយោបាយជាមួយគ្នា ខ្ញុំសង្ឃឹមថា ក្រោយពេលការសិក្សាផ្នែកនយោបាយនេះត្រូវបានបញ្ចប់ទៅ យើងនឹងបានបំពេញការងារ ដ៏មានប្រយោជន៍ជាច្រើនសម្រាប់ជាតិរបស់យើងទាំងអស់គ្នា។ ខ្ញុំសង្ឃឹមថា និក្ខេបបទថ្នាក់បណ្ឌិត ដែលខ្ញុំបានស្រាវជ្រាវនេះ នឹងបានជាប្រយោជន៍ខ្លះៗ ដល់ប្រជាជនកម្ពុជា ជាពិសេសអ្នក ដែលចង់សិក្សាពីវិស័យការទូតកម្ពុជាអាម៉េរិក។

សូមអរព្រះគុណ និងសូមអរគុណ!

# អំណះអំណាង

ខ្ញុំសូមធានាអះអាងថានិក្ខេបបទស្រាវជ្រាវថ្នាក់បណ្ឌិតស្តីពី **"ទំនាក់ទំនងនយោបាយកម្ពុជា-សហរដ្ឋអាមេរិក"** ពិតជាកើតឡើងចេញពីការស្រាវជ្រាវផ្អែកលើមូដ្ឋានវិទ្យាសាស្ត្រដោយមានការយោងឯកសាររឹងមាំ និងអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវ និងនិក្ខេបបទនៃសាកលវិទ្យាល័យខេមរៈ ដោយមិនមានជាន់ស្នាដៃអ្នកនិពន្ធផ្សេងក្នុងប្រទេសកម្ពុជានោះឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៩

**ហត្ថលេខា**

**ឈ្មោះ ស៊ឺន សំ**

**បានពិនិត្យ និងឯកភាព**

រាជធានីភ្នំពេញ, ថ្ងៃទី...៣១.......ខែ..ធ្នូ...... ឆ្នាំ២០១៩

**សាស្ត្រាចារ្យណែនាំ**

**បណ្ឌិតសភាចារ្យ សុខ ទូច**

# មូលន័យសង្ខេប

បទពិសោធន៍ក្នុងការដោះស្រាយជម្លោះផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ នៅក្នុងទសវត្សឆ្នាំ១៩៩០ ធ្វើឱ្យកម្ពុជាក្លាយជាគំរូដ៏ល្អដល់ប្រទេសមួយចំនួននៅក្នុងពិភពលោក។ វត្តមានរបស់ក្រុមមេដឹកនាំកំពូលពិភពលោកនៅក្នុងប្រទេសកម្ពុជា ជាការទាក់ទាញនូវការចាប់អារម្មណ៍ពីសំណាក់សាធារណជនដែលជាអ្នកតាមដានស្ថានការណ៍នយោបាយការបរទេស និងពីសំណាក់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាខ្លាំង។ រដ្ឋាភិបាលកម្ពុជាត្រូវធ្វើយ៉ាងណាធានាឱ្យបាននូវសន្តិសុខ សុវត្ថិភាព ស្ថេរភាពនយោបាយ ស្ថេរភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច សណ្តាប់ធ្នាប់សង្គម ជាអ្វីដែលកម្ពុជាកំពុងមាននាពេលបច្ចុប្បន្ននេះ ហើយវាក៏ជាស្នូលដែលជម្រុញឱ្យកម្ពុជាមានការអភិវឌ្ឍន៍ខាងផ្នែកសេដ្ឋកិច្ចផងដែរ។

កម្ពុជានាពេលបច្ចុប្បន្ន ជាប្រទេសមួយដែលមានការទាក់ទាញពីអ្នកវិនិយោគបរទេសគួរឲ្យកត់សម្គាល់លើគ្រប់វិស័យដែលមានសក្តានុពល រួមមាន កសិកម្ម សេវាកម្ម ទេសចរណ៍ជាដើម។ ទន្ទឹមគ្នានេះ កម្ពុជាត្រូវតែរៀបចំខ្លួនឲ្យបានសមស្រប ក្នុងការទាញយកឲ្យអស់លទ្ធភាព ពីការវិនិយោគទាំងនោះ។ មានន័យថា កម្ពុជាត្រូវតែមាននយោបាយរយៈពេលខ្លី និងវែង ដើម្បីទាញផលប្រយោជន៍ទាំងអស់ពីមហាអំណាច ដែលជាអ្នករកស៊ីឲ្យមកវិនិយោគនៅកម្ពុជា។ ជាពិសេសកម្ពុជា មិនត្រូវមានទំនាក់ទំនងល្អតែជាមួយប្រទេសមួយនោះទេ។ ការមានមិត្តច្រើនជាឱកាសរបស់កម្ពុជាដើម្បីពង្រីកសេដ្ឋកិច្ច និងស្វែងរកទីផ្សារ។

ក្នុងចន្លោះឆ្នាំ ១៩៥៥ ដល់១៩៦៣ សហរដ្ឋអាម៉េរិក បានផ្តល់ជំនួយឧបត្ថម្ភផ្នែកសេដ្ឋកិច្ចចំនួន ៤០៩,៦ លានដុល្លា និង៣៨,៧ លានដុល្លាផ្សេងទៀតជាជំនួយលើផ្នែកយោធា។ ជំនួយដ៏ច្រើនបែបនេះ ត្រូវបានយកទៅប្រើប្រាស់ដើម្បីជួសជុលការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ដែលបណ្តាលមកពីសង្គ្រាមឥណ្ឌូចិនលើកទី១ និងជួយពង្រឹងកម្លាំងសន្តិសុខផ្ទៃក្នុង ស្ថាបនាសំណង់ធំៗ ដូចជា ផ្លូវថ្នល់ និងស្ពាន ពីភ្នំពេញទៅទៅកំពង់ផែក្រុងព្រះសីហនុ ដែលមានចម្ងាយ២១៤គីឡូម៉ែត ដើម្បីបើកច្រកប្រទេសកម្ពុជាទៅកំពង់ផែទឹកជ្រៅ។ ប៉ុន្តែជំនួយនេះ បានថយចុះជាបន្តបន្ទាប់ រហូតដល់មានការបដិសេធជំនួយពីអាម៉េរិកទាំងស្រុងនៅឆ្នាំ ១៩៦៣ ដោយមូលហេតុខ្វែងទស្សនៈគ្នា រវាងកម្ពុជា និងអាម៉េរិក។

ពីឆ្នាំ១៩៧០-១៩៧៥ អាម៉េរិកបានងាកមកគាំទ្ររបបសាធារណរដ្ឋខ្មែរ របស់ លន់ នល់ ជារបបសេរីស្និទ្ធនឹងអាមេរិកាំង ប៉ុន្តែអ្វីដែលនៅពីក្រោយសម្ព័ន្ធមិត្តនោះគឺ សង្គ្រាមដែលចាប់ផ្តើមឆាបឆេះប្រទេសកម្ពុជាក្នុងលក្ខណៈជាសង្គ្រាមបែបមនោគមន៍វិជ្ជារវាងប្លុកសេរី និងប្លុកកុំម្មុយនីស្ត។ របបលន់ លន់ ក្នុង រយៈពេល៥ឆ្នាំ សហរដ្ឋអាម៉េរិកបានផ្តល់ជំនួញជាថវិកា១,១៨០លានដុល្លា លើផ្នែកយោធា និង៥០៣លានដុល្លាទៀត លើផ្នែកសេដ្ឋកិច្ច។ គេឃើញមានការផ្លាស់ប្តូរដ៏ឆាប់រហ័សគួរឱ្យកត់សម្គាល់មួយ ក្នុងនយោបាយរបស់អាម៉េរិកនោះ គឺនៅឆ្នាំ១៩៧៥ គេទទួលដំណឹងដ៏ទាន់ហាន់អំពីការយាងមកកាន់ប្រទេសវិញរបស់សម្តេចនរោត្តមសីហនុ។ ចំពោះព្រឹត្តិការណ៍នេះ អាម៉េរិកបានយល់ព្រមទាំងស្រុងតាមសំណើររបស់ព្រះអង្គ។ ដោយស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជននៅទីក្រុងភ្នំពេញ អាម៉េរិកសុខចិត្តប្រគល់តួនាទីជាអ្នកដឹកនាំប្រទេស ថ្វាយសម្តេចនរោត្តមសីហនុ ហើយបានសំណូមពរឱ្យលោក លន់ នល់ ចាកចេញពីប្រទេសកម្ពុជា ទៅកោះហាវ៉ៃ ចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៥ ។

ឆ្នាំ ១៩៧៩-១៩៨៩ អាម៉េរិក បានជំទាស់នឹងអន្តរាគមន៍របស់កងទ័ពវៀតណាម ដែលចូលមកកម្ពុជា ហើយថែមទាំងទាមទារឱ្យវៀតណាមដកទ័ពចេញពីកម្ពុជាទៀតផង។ អាម៉េរិកបានបោះឆ្នោតគាំទ្រអាសនៈកម្ពុ

ជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ ដែលកាលនោះលោកប្រធានាធិបតី Hodding Carter ធ្លាប់បានឱ្យឈ្មោះថា *«របបដែលរំលោភសិទ្ធិមនុស្សធំជាងគេបំផុត»* ដើម្បីតម្រូវចិត្តចិនដែលខ្លួនកំពុងតែរួមដំណើរជាមួយ។ ហើយនៅឆ្នាំ១៩៨៩ ដល់១៩៩៣ ជាដំណាក់កាលនៃទំនាក់ទំនងកម្ពុជាអាម៉េរិក ឈានឆ្ពោះទៅការបញ្ចប់ជម្លោះនៅកម្ពុជា៕

ប្រធានបទស្តីពី *ទំនាក់ទំនងនយោបាយកម្ពុជា-សហរដ្ឋអាម៉េរិក* នឹងបានជាពន្លឺមួយដើម្បីជួយស្រាយនូវចម្ងល់របស់មហាជនទូទៅ ស្តីពីវឌ្ឍនភាព និងមេរៀននយោបាយដែលកម្ពុជាបានឆ្លងកាត់ក្រោយពីការទទួលបានឯករាជ្យ។ ព្រះរាជាណាចក្រកម្ពុជាមិនអាចមានទំនាក់ទំនងតែជាមួយប្រទេសណាមួយនោះទេ គឺត្រូវមានទំនាក់ទំនងជាមួយប្រទេសទាំងអស់ក្នុងលោក បើទោះបីជាពេលខ្លះ មានការប៉ះទង្គិចនយោបាយជាមួយគ្នាម្តងម្កាលក៏ដោយ ប៉ុន្តែភូមិសាស្ត្រនយោបាយពិភពលោក គឺសហរដ្ឋអាម៉េរិកមិនអាចខ្វះកម្ពុជាបាន ហើយកម្ពុជាក៏មិនអាចខ្វះទីផ្សារអាម៉េរិកបានដែរ។

លទ្ធផលនៃស្នាដៃសិក្សាស្រាវជ្រាវនេះ នឹងផ្តល់នូវចំណេះដឹង និងបទពិសោធន៍សំខាន់ៗ មួយចំនួនពាក់ព័ន្ធនឹងមូលហេតុនាំឱ្យមានជម្លោះនយោបាយ និង យន្តការដោះស្រាយនានា ព្រមទាំងទស្សនៈផ្សេងៗដែលបានមកពីបញ្ញវន្ត អ្នកការទូត និង អ្នកនយោបាយ កម្ពុជា-អាម៉េរិក និងទស្សនៈអ្នកវិភាគនយោបាយពីបណ្តាប្រទេសផ្សេងៗ រួមនឹងទស្សនៈយល់ឃើញផ្ទាល់ខ្លួនរបស់យើងខ្ញុំផងដែរ។

## ABSTRACT

The successful internal conflict resolution in the 1990s made Cambodia a great example for many countries in the world. The presence of the world's top leaders in Cambodia has attracted the attention of the public, who are monitoring the situation of foreign policy and of the national and international journalists. The Cambodian government needs to ensure security, security, political stability, macroeconomic stability, social order since it is at the core of its economic development.

Cambodia is currently a country with significant foreign investment in all areas of potential, including agriculture, tourism services and so on. At the same time, Cambodia must be properly prepared to exploit those investments. It means that Cambodia must have a short and long term policy in order to exploit all the power of the business elite to invest in Cambodia. In particular, Cambodia must not only have good relations with one country. Having more friends is Cambodia's opportunity to grow and develop markets.

The relations of both countries in 1950-1970: from 1955 to 1963, the United States of America donated fund to support Cambodia economic for USD 409, 6 million, and USD 38, 7 million to support Cambodia military. Due to big amount of funding supports from the United States of America at that time, Cambodian government had transferred that fund to rebuild infrastructures that were destroyed by first Indochina war, to strengthen internal security, built road and bridge from Phnom Penh to Sihanoukville that longed 214 km in order to open water gate in Cambodia. But that kind of fund was reduced virtually until Cambodia rejected whole donation from the United States due to different understanding between Cambodia and US at that time.

From 1970 to 1979, the United States had changed to support Khmer Republic of Marshal Lon Nol, which is the regime closed to American government. But main thing behind that relationship is ideological war between communist and free blocs. Five years under the leadership of Lon Nol regime, the United States supported USD 1,180 million for military and USD 503 million for economic. But there was one remarkable change in American politics with Cambodia at that time; in 1975 that was a fast news about repatriation of King Noromdom Sihanouk, and the United States had totally agreed with the proposal of the King Norodom Sihanouk, and that repatriation is fit to heart and request of Cambodian people living in Phnom Penh at that time, the US agreed to offer role as state-man to King Norodom Sihanouk and the US requested Marshal Lon Nol to leave Cambodia and flied to Hawai on March 31, 1975.

From 1979 to 1989, the United States of America has objected to the intervention of Vietnam into Cambodia, and had requested Vietnam to withdraw their military from Cambodia. Furthermore, the US has voted to support the seat of democratic Kampuchea at the United Nations ( UN), which president Hodding Carter used to call as " The Regime with serious human rights violation in the world" in order to convince China that was walking the same road with them. And from 1989 to 1993, is the phase of relations of Cambodia and the US to end conflict in Cambodia.

The topic on Political Relations of Cambodia-United States of America will be one guidance to depict the progress and political lessons which Cambodia has gone through after receiving independence. Furthermore, situation of the world today showed that Cambodia cannot has good relations only with one specific nation but all countries in the world, even sometimes there is political clash with each other, but in world geopolitics, as the realities US cannot treat Cambodia as not important state, and Cambodia is honestly need US 's market.

Results of this research will provide knowledge and crucial experiences related to political conflicts, and other mechanical solutions as well as other aspects which was absorbed from scholars, diplomats, and Cambodian and American politicians, and other political analysis aspects including our perspectives.